# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

NATIONAL AIDS AUTHORITY

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

លេខ :.......១២២.......អ.ជ.ប.ជ.អ

ភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១២

## គោលការណ៍ណែនាំ
## ស្តីពី
## ការពង្រឹងការអនុវត្តន៍កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដើម្បីឈានឆ្ពោះទៅកាត់ផ្តាច់ការចម្លងនៅត្រឹមឆ្នាំ២០១៥

- យោងព្រះរាជក្រមលេខនស.រកម.០៧០២.០១៥ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)
- យោងអនុក្រឹត្យលេខ១០៩អ.ន.ក្រ.បកចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យោងសារណែនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលរួមអបអរសាទរការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ នាថ្ងៃទី២៩ខែវិច្ឆិកាឆ្នាំ២០១១
- យោងសេចក្តីថ្លែងការណ៍នាសម័យប្រជុំពិសេសមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីជំងឺអេដស៍នៅថ្ងៃទី៨-១០ខែមិថុនាឆ្នាំ២០១១នៅទីស្នាក់ការកណ្តាលអង្គការ សហប្រជាជាតិនា បូរីញូវយ៉កសហរដ្ឋអាមេរិកដែលក្នុងនោះប្រទេសជាសមាជិកទាំងអស់បានប្តេជ្ញាចិត្តចូលរួមក្នុងការកាត់ផ្តាច់ទាំងស្រុងនូវការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យបានត្រឹមឆ្នាំ២០១៥
- យោងផែនការយុទ្ធសាស្ត្រជាតិពហុវិស័យលើកទី៣ ឆ្នាំ២០១១-២០១៥
- យោងសន្និបាតបូកសរុបការងារឆ្នាំ២០១១និងទិសដៅឆ្នាំ២០១២ និងកិច្ចប្រជុំពេញអង្គសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថ្ងៃទី១៥-១៦ ខែមីនា ឆ្នាំ២០១២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កំណត់គោលការណ៍ណែនាំស្តីពីការពង្រឹងការអនុវត្តន៍កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដើម្បីឈានឆ្ពោះទៅកាត់ផ្តាច់ការចម្លងទាំងស្រុងនៅត្រឹមឆ្នាំ២០១៥ ដូចខាងក្រោម៖

### ១.ថ្នាក់ជាតិ

ក- ក្រុមការងារថ្នាក់ជាតិលើយុទ្ធសាស្ត្របង្ការ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវដឹកនាំគ្រប់គ្រងសម្របសម្រួល និងសហការជាមួយអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិលដែលពាក់ព័ន្ធនឹងការងារនេះតាមគ្រប់រូបភាព ដើម្បីបំពេញគម្លាតក្នុងការរៀបចំអនុវត្ត និងតាមដាននូវគោលនយោបាយយុទ្ធសាស្ត្រជាតិដែលធានាដល់លទ្ធភាព និងប្រសិទ្ធភាពធនធានបច្ចេកទេសសម្ភារៈនិងថវិកាឈានទៅសម្រេចការកាត់ផ្តាច់ទាំងស្រុងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

ខ- ក្រុមការងារថ្នាក់ជាតិលើយុទ្ធសាស្ត្រទាំងប្រាំមួយផ្សេងទៀត របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវចូលរួមសហការសម្របសម្រួលដើម្បីជំរុញអោយការអនុវត្តន៍កម្មវិធីមានប្រសិទ្ធភាពខ្ពស់។

គ- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងសុខាភិបាល ត្រូវបន្តពង្រឹង និងពង្រីកប្រពន្ធ័ផ្តល់សេវាដើម្បីសម្រួលដល់ប្រជាពលរដ្ឋជាពិសេសនៅតំបន់ដាច់ស្រយាល។

ឃ- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងពាក់ព័ន្ធ ជាពិសេសក្រសួងកិច្ចការនារី ត្រូវជំរុញ និងសម្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យកម្មវិធីបង្ការការចម្លងពីម្តាយទៅកូនទទួលបានជោគជ័យ។

ង- ក្រុមការងារថ្នាក់ជាតិលើយុទ្ធសាស្ត្រត្រួតពិនិត្យ តាមដាននិងវាយតម្លៃ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវពិនិត្យ តាមដាន វាយតម្លៃការអនុវត្តន៍ដាក់ជូនសន្និបាតប្រចាំឆ្នាំដើម្បីធ្វើការពិចារណានិងផ្តល់អនុសាសន៍កែលំអជំរុញការអនុវត្តន៍បន្ត។

**២.ថ្នាក់ក្រោមជាតិ**

**២.១ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុកខ័ណ្ឌ**

ក- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវចូលរួមអនុវត្តសេចក្តីណែនាំតាមការដឹកនាំ គ្រប់គ្រង សម្របសម្រួល និងសហការជាមួយដៃគូសង្គមស៊ីវិលដែលពាក់ព័ន្ធនឹងការងារនេះតាមគ្រប់រូបភាពដើម្បីបំពេញគម្លាតក្នុងការរៀបចំអនុវត្ត ដែលធានាដល់លទ្ធភាព និងប្រសិទ្ធភាពធនធានបច្ចេកទេសសម្ភារៈ និងថវិកាឈានទៅសម្រេចការកាត់ផ្តាច់ទាំងស្រុងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

ខ- រាល់កិច្ចប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវមានស្ថិតិក្រុមគោលដៅជាស្ត្រីមានផ្ទៃពោះ និងសេវាផ្តល់ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដើម្បីជំរុញ និងជួយបង្កលក្ខណៈងាយស្រួលអោយស្ត្រីមានផ្ទៃពោះមកទទួលសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានត្រឹមត្រូវ និងគ្រប់ៗគ្នា។

គ- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវពង្រឹងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពក្នុងការផ្តល់សេវាជូនស្ត្រីមានផ្ទៃពោះឱ្យបានគ្រប់ៗគ្នា។

ឃ- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ត្រូវជំរុញមន្ទីរពាក់ពន្ធ័ទាំងអស់ ជាពិសេសមន្ទីរកិច្ចការនារីឱ្យសហការអនុវត្តសកម្មភាពផ្តល់លទ្ធភាពជូនស្ត្រីមានផ្ទៃពោះឱ្យមកទទួលសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

ង- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ត្រូវត្រួតពិនិត្យ តាមដាន វាយតម្លៃការអនុវត្តន៍ជាប្រចាំ។

**២.២ ថ្នាក់ឃុំ- សង្កាត់**

ក- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយគណៈកម្មការនារី និងកុមារឃុំ-សង្កាត់ ប្រធានភូមិ និងអ្នកស្ម័គ្រចិត្តសុខភាពភូមិ ដែលធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីទទួលបានទិន្នន័យស្ត្រីមានផ្ទៃពោះជាប្រចាំ និងជំរុញឱ្យមកពិនិត្យផ្ទៃពោះគ្រប់ៗគ្នានៅមណ្ឌលសុខភាព។

ខ- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយអង្គការសង្គមស៊ីវិល និងកាកបាទក្រហមកម្ពុជាចូលរួមអប់រំ ផ្សព្វផ្សាយដល់ប្រជាជន ជាពិសេសស្ត្រីមានផ្ទៃពោះឱ្យបានយល់ដឹង និងចូលរួមស្វែងរកការថែទាំ និងព្យាបាលឱ្យបានត្រឹមត្រូវនៅមណ្ឌលសុខភាព។

គ- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍សហការជាមួយប៉ូលីសប៉ុស្តិ៍ ប្រធានភូមិ ត្រូវផ្តល់ការអប់រំដល់បុរសជាស្វាមីឱ្យបានយល់ដឹងពីជំងឺអេដស៍ អំពីសារៈសំខាន់នៃការពិនិត្យផ្ទៃពោះ និងការចូលរួមរបស់ស្វាមី។

ឃ- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ត្រូវសហការជាមួយអង្គការសង្គមស៊ីវិល និងកាកបាទក្រហមកម្ពុជាដើម្បីផ្តល់លទ្ធភាព មធ្យោបាយធ្វើដំណើរជូនស្ត្រីមានផ្ទៃពោះក្រីក្រឱ្យមកទទួលសេវាថែទាំផ្ទៃពោះនៅមណ្ឌលសុខភាព។

ង- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយមណ្ឌលសុខភាព ដើម្បីផ្តល់សេវាពិនិត្យផ្ទៃពោះ និងផ្តល់កិច្ចប្រឹក្សាឈានទៅធ្វើតេស្តឈាមរកមេរោគអេដស៍ និងបន្តផ្តល់សេវាបង្ការ ថែទាំ ព្យាបាលនិងគាំទ្រជូនស្ត្រីមានផ្ទៃពោះក្នុងករណីចាំបាច់។

ច- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវរៀបចំកិច្ចប្រជុំទៀងទាត់ ដើម្បីដឹកនាំគ្រប់គ្រង និងសម្របសម្រួលក្នុងការរៀបចំផែនការពង្រឹងកិច្ចសហការណ៍ ជំរុញការអនុវត្តន៍តាមដាន និងវាយតម្លៃ។

ទទួលបាននូវគោលការណ៍ណែនាំនេះ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**វេជ្ជ. នុត-សុខុម**

**__ចម្លងជូន:__**

- គណៈកម្មការទី៨នៃព្រឹទ្ធសភា
- គណៈកម្មការទី៨នៃរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យ ឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី
- កាកបាទក្រហមកម្ពុជា (ដើម្បីជូនជ្រាបជាព័ត៌មាន)
- ដៃគូអភិវឌ្ឍន៍
- សង្គមស៊ីវិល(ដើម្បីសហការ)
- ឯកសារ-កាលប្បវត្តិ